# សេចក្តីណែនាំស្តីពីការបំពេញទិន្នន័យក្នុងបញ្ជីកត់ត្រា ផ្នែកពិគ្រោះជំងឺក្រៅ សម្រាប់មន្ទីរពេទ្យ

*បោះពុម្ពលើកទី១, ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣*

កំណត់សម្គាល់ ៖

- បញ្ជីកត់ត្រានេះត្រូវប្រើនៅកន្លែងពិនិត្យពិគ្រោះជំងឺក្រៅ សម្រាប់កត់ត្រាអ្នកជំងឺដែលមកពិគ្រោះជំងឺក្រៅទាំងមនុស្សចាស់ និងកុមារ។ (មិនត្រូវកត់ត្រានូវសកម្មភាពសេវាការពារដូចជា ការចាក់ថ្នាំបង្ការ ពិនិត្យផ្ទៃពោះ ពន្យាកំណើត ជាដើម និងការសម្រាលកូន ការថែទាំក្រោយសម្រាល)។
- បិទបញ្ជីនៅថ្ងៃចុងក្រោយនៃខែនីមួយៗ។
- សម្រាប់ខែថ្មី កាលបរិច្ឆេទត្រូវសរសេរនៅចំកណ្តាលទំព័រថ្មីនៃសៀវភៅកត់ត្រា។

ត្រូវបំពេញព័ត៌មានលម្អិតនៅបន្ទាត់ (ជួរផ្តេក) តាមការណែនាំខាងក្រោមនូវគ្រប់ករណីទាំងអស់ ៖

| ខ្ទង់ទី | សេចក្តីណែនាំ |
|---|---|
| ១ | *លេខរៀង*<br>ជាលេខរៀង(លេខស្ទីត)តាមលំដាប់ដែលអ្នកជំងឺមកពិគ្រោះជំងឺក្រៅ ការណាត់ជួប និងការពិនិត្យសុខភាពផ្សេងៗ។ លេខរៀងនេះត្រូវចាប់ផ្តើមពីលេខ១ និងលេខបន្តបន្ទាប់រហូតដល់ដាច់ខែ។ ចាប់ផ្តើមលេខរៀងថ្មី(លេខស្ទីត) នៅរៀងរាល់ខែថ្មី។ |
| ២ | *លេខកូដអ្នកជំងឺ*<br>ត្រូវចម្លងលេខពីលេខកូដអ្នកជំងឺរបស់មន្ទីរពេទ្យ។ ឧទាហរណ៍៖ 000-000-123-1។ |
| ៣ | *ឈ្មោះអ្នកជំងឺ*<br>សរសេរឈ្មោះពេញ (នាមត្រកូល និងនាមខ្លួន) របស់អ្នកជំងឺដែលមកទទួលសេវា ពិគ្រោះជំងឺក្រៅ ការណាត់ជួប និងការពិនិត្យសុខភាពផ្សេងៗ។ |
| ៤ | *ឈ្មោះអាណាព្យាបាល (សម្រាប់កុមារ)*<br>សរសេរឈ្មោះពេញ (នាមត្រកូល និងនាមខ្លួន) របស់អាណាព្យាបាលកុមារ។ |
| ៥ | *អាយុ៖ 0-២៨ ថ្ងៃ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី 0ថ្ងៃ រហូតដល់ ២៨ថ្ងៃ។ ឧទាហរណ៍៖ អាយុ ២0ថ្ងៃ សរសេរលេខ ២0។ |
| ៦ | *អាយុ៖ ២៩ថ្ងៃ-១១ខែ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ២៩ថ្ងៃ រហូតដល់ ១១ខែ។ ឧទាហរណ៍៖ អាយុ ៣0ថ្ងៃ ឬ ១0ខែ ត្រូវសរសេរបញ្ជាក់ថ្ងៃ ឬខែអោយច្បាស់។ |
| ៧ | *អាយុ៖ ១-៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ១ឆ្នាំ រហូតដល់ ៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៣ឆ្នាំ សរសេរ ៣។ |


នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល
ការិយាល័យប្រព័ន្ធព័ត៌មាន
USAID ជំនួយពីប្រជាជនអាមេរិក
BETTER HEALTH SERVICES
URC Cambodia

| ខ្ទង់ទី | សេចក្ដីណែនាំ |
|---|---|
| ៨ | *អាយុ៖ ៥-១៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្ដែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ៥ឆ្នាំ រហូតដល់ ១៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៥ឆ្នាំ សរសេរ ៥។ |
| ៩ | *អាយុ៖ ១៥-២៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្ដែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ១៥ឆ្នាំ រហូតដល់ ២៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ២០ឆ្នាំ សរសេរ ២០។ |
| ១០ | *អាយុ៖ ២៥-៤៩ ឆ្នាំ*<br>សរសេរអាយុជាក់ស្ដែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ២៥ឆ្នាំ រហូតដល់ ៤៩ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៣៥ឆ្នាំ សរសេរ ៣៥។ |
| ១១ | *អាយុ៖ ៥០-៦៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្ដែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ៥០ឆ្នាំ រហូតដល់ ៦៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៥៥ឆ្នាំ សរសេរ ៥៥។ |
| ១២ | *អាយុ៖ ≥៦៥ ឆ្នាំ*<br>សរសេរអាយុជាក់ស្ដែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ៦៥ឆ្នាំ ឡើងទៅ។ ឧទាហរណ៍៖ អាយុ ៦៦ឆ្នាំ សរសេរ ៦៦។ |
| ១៣ | *ភេទ៖ ប្រុស*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺភេទប្រុស។<br>ឧទាហរណ៍៖ ១, ២, ៣... |
| ១៤ | *ភេទ៖ ស្រី*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺភេទស្រី។<br>ឧទាហរណ៍៖ ១, ២, ៣... |
| ១៥ | *អាស័យដ្ឋានបច្ចុប្បន្ន និងលេខទូរស័ព្ទ*<br>សរសេរអាស័យដ្ឋានបច្ចុប្បន្នរបស់អ្នកជំងឺដែលមកទទួលសេវាមន្ទីរពេទ្យ។ ត្រូវសរសេរភូមិ ឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ រាជធានី/ខេត្ត និងលេខទូរស័ព្ទ។ |
| ១៦ | *បញ្ជូនមកពី៖ ក្នុងស្រុកប្រតិបត្តិ/ខេត្ត (ថ្មី)*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺមកទទួលសេវាពិគ្រោះជំងឺក្រៅជាករណីថ្មី ដែលបានបញ្ជូនមកពីក្នុងស្រុកប្រតិបត្តិ របស់ខ្លួនផ្ទាល់។<br>ឧទាហរណ៍៖ ១, ២, ៣... |
| ១៧ | *បញ្ជូនមកពី៖ ក្រៅស្រុកប្រតិបត្តិ/ខេត្ត (ថ្មី)*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺមកទទួលសេវាពិគ្រោះជំងឺក្រៅជាករណីថ្មី ដែលបានបញ្ជូនមកពីក្រៅស្រុកប្រតិបត្តិ ឬខេត្តរបស់ខ្លួន (ស្រុកប្រតិបត្តិ/ខេត្តផ្សេង)។ ឧទាហរណ៍៖ ១, ២, ៣... |
| ១៨ | *មកពិនិត្យដោយខ្លួនឯង៖ ក្នុងស្រុកប្រតិបត្តិ (ថ្មី)*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺមកដោយខ្លួនឯងជាករណីថ្មី និងស្ថិតក្នុងស្រុកប្រតិបត្តិរបស់ខ្លួន។ ឧទាហរណ៍៖ ១, ២, ៣... |
| ១៩ | *មកពិនិត្យដោយខ្លួនឯង៖ ក្នុងស្រុកប្រតិបត្តិ (ចាស់)*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺមកដោយខ្លួនឯងជាករណីចាស់ ដែលស្ថិតក្នុងស្រុកប្រតិបត្តិរបស់ខ្លួន។ ឧទាហរណ៍៖ ១, ២, ៣... |
| ២០ | *មកពិនិត្យដោយខ្លួនឯង៖ ក្រៅស្រុកប្រតិបត្តិ/ខេត្ត (ថ្មី)*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺមកដោយខ្លួនឯងជាករណីថ្មី និងមកពីក្រៅស្រុកប្រតិបត្តិ ឬខេត្តផ្សេង។ ឧទាហរណ៍៖ ១, ២, ៣... |

| ខ្ទង់ទី | សេចក្តីណែនាំ |
|---|---|
| ២១ | *មកពិនិត្យដោយខ្លួនឯង៖ ក្រៅស្រុកប្រតិបត្តិ/ខេត្ត (ចាស់)*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺមកដោយខ្លួនឯងជាករណីចាស់ និងមកពីក្រៅស្រុកប្រតិបត្តិ ឬខេត្តផ្សេង។ ឧទាហរណ៍៖ ១, ២, ៣... |
| ២២ | *មានផ្ទៃពោះ (សប្តាហ៍)*<br>ត្រូវសរសេរអាយុផ្ទៃពោះ (ប្រសិនបើជាស្ត្រីដែលកំពុងមានគភ៌) គិតជាសប្តាហ៍ដោយ រាប់ចាប់ពីថ្ងៃទីមួយនៃការបាត់រដូវចុងក្រោយ។ ឧទាហរណ៍៖ស្ត្រីមានអាយុផ្ទៃពោះ០៧សប្តាហ៍ ត្រូវសរសេរតែលេខ០៧ប៉ុណ្ណោះ។ |
| ២៣ | *រោគសញ្ញា*<br>សរសេររោគសញ្ញាផ្សេងៗ ដែលអ្នកជំងឺបានរៀបរាប់ប្រាប់។ |
| ២៤ | *អមវេជ្ជសាស្ត្រ*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើគ្រូពេទ្យស្នើសុំសេវាអមវេជ្ជសាស្ត្រ<br>ឧទាហរណ៍៖ ១, ២, ៣... |
| ២៥ | *រោគវិនិច្ឆ័យ*<br>សរសេររោគវិនិច្ឆ័យរបស់អ្នកជំងឺដែលកំណត់ដោយគ្រូពេទ្យ។ |
| ២៦ | *ការព្យាបាល*<br>សរសេរវេជ្ជបញ្ជារបស់គ្រូពេទ្យដែលបានផ្តល់អោយអ្នកជំងឺ។<br>ឧទាហរណ៍៖ Para 500mg 1c X 3, Vit.C 500mg 1c X 2, Amoxillin 500mg 1c X 3 |
| ២៧ | *ស្ថានភាពអាហារូបត្ថម្ភពេលចូល៖ ទម្ងន់/អាយុ (ប័ណ្ណលឿង)*<br>ថ្លឹងទម្ងន់របស់កុមារ<br>កំណត់ទម្ងន់របស់កុមារធៀបនឹងអាយុដោយប្រើប័ណ្ណលឿង៖<br>១. សរសេរ R ប្រសិនបើទម្ងន់ធៀបនឹងអាយុឋិតក្នុងតំបន់ពណ៌ក្រហម<br>២. សរសេរ O ប្រសិនបើទម្ងន់ធៀបនឹងអាយុឋិតក្នុងតំបន់ពណ៌ទឹកក្រូច<br>៣. សរសេរ G ប្រសិនបើទម្ងន់ធៀបនឹងអាយុឋិតក្នុងតំបន់ពណ៌បៃតង |
| ២៨ | *ស្ថានភាពអាហាររូបត្ថម្ភពេលចូល៖ ទម្ងន់/កម្ពស់*<br>ថ្លឹងទម្ងន់របស់កុមារ ។ វាស់ប្រវែង/កម្ពស់របស់កុមារ (ឲ្យកុមារដេកបើអាយុក្រោម២ឆ្នាំ ឬ ឲ្យឈរបើអាយុចន្លោះពី២ទៅ៥ឆ្នាំ)។ កំណត់ទម្ងន់របស់កុមារធៀបនឹងកម្ពស់ (គម្លាតស្តង់ដា [SD]) (ឧទាហរណ៍ -៣SD, -២SD, -១SD, ឬ ធម្មតា) ដោយប្រើប្រាស់តារាងស្តង់ដាទម្ងន់ធៀបកម្ពស់របស់អង្គការសុខភាពពិភពលោក ។ ចូរប្រើផ្នែកខាងស្តាំនៃតារាងសម្រាប់ក្មេងប្រុស និងផ្នែកខាងឆ្វេងនៃតារាងសម្រាប់ក្មេងស្រី ។ ចូរសរសេរ:-៣, -២, -១,ឬ 0 សម្រាប់ធម្មតា។ |
| ២៩ | *បញ្ជូនទៅ (ទៅក្រៅ/សម្រាកពេទ្យ)*<br>សរសេរឈ្មោះទីកន្លែងដែលបានបញ្ជូនអ្នកជំងឺទៅទាំងក្នុងមន្ទីរពេទ្យ និងបញ្ជូនទៅកាន់មន្ទីរពេទ្យ ឬសេវាឯកជនផ្សេងៗ។ |
| ៣០ | *ប្រភេទនៃការបង់ថ្លៃសេវា*<br>1. សរសេរ P: សម្រាប់ការបង់លុយដោយខ្លួនឯង។<br>2. សូមសរសេរ HEF: សម្រាប់ការបង់ដោយគំរោងមូលនិធិសមធម៌។<br>3. សូមសរសេរ CBHI: សម្រាប់ការបង់ដោយគំរោងធានារ៉ាប់រងសហគមន៍។<br>4. សូមសរសេរ V(Voucher): ប្រសិនបើគាត់មានប័ណ្ណសុខភាព។<br>5. សូមសរសេរ E: សម្រាប់ករណីលើកលែង។<br><br>*ចំណាំ៖ រាល់ការបង់ថ្លៃសេវាដោយ HEF ឬ CBHI ឬ V សូមសរសេរលេខកូដដែលស្រង់ចេញពីប័ណ្ណនោះក្នុងខ្ទង់សម្គាល់។* |
| ៣១ | *សម្គាល់*<br>ត្រូវសរសេរចំនុចសម្គាល់ផ្សេងៗ ដែលចាំបាច់ទាក់ទងទៅនឹងអ្នកជំងឺ។ |

# សម្រង់តួលេខប្រចាំថ្ងៃ ពិនិត្យពិគ្រោះជំងឺក្រៅសម្រាប់មន្ទីរពេទ្យ

| នៃខែ.............ឆ្នាំ............ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| រោគវិនិច្ឆ័យ | អាយុ Group | ករណី | ភេទ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | Total |
| (សរសេររោគវិនិច្ឆ័យ) | (សរសេរ ក្រុមអាយុ) | ឈឺ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ខ. របួសដោយគ្រោះថ្នាក់ចរាចរណ៍ក្រៅពីប៉ះទង្គិចក្បាល | 15-24 ឆ្នាំ | ឈឺ | ប្រុស | 3 | 2 | | 2 | 2 | 1 | 1 | 1 | 1 | | 1 | 1 | 2 | 2 | 1 | 2 | 2 | 2 | 2 | | 1 | | 1 | 1 | | 1 | 1 | | | 2 | 3 | មិនបាច់បំពេញ |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | បញ្ជូនទៅ | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | HEF: បង់ដោយមូលនិធិសមធម៌ | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

# សម្រង់តួលេខសរុបប្រចាំថ្ងៃ ផ្នែកពិគ្រោះជំងឺក្រៅសម្រាប់មន្ទីរពេទ្យ

| នៃខែ.............ឆ្នាំ............ | | | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | Total |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បញ្ជូនមកពី | ក្នុងស្រុកប្រតិបត្តិ/ខេត្ត | ថ្មី | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | ក្រៅស្រុកប្រតិបត្តិ/ខេត្ត | ថ្មី | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| មកពិនិត្យដោយខ្លួនឯង | ក្នុងស្រុកប្រតិបត្តិ/ខេត្ត | ថ្មី | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | ចាស់ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | ក្រៅស្រុកប្រតិបត្តិ/ខេត្ត | ថ្មី | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | ចាស់ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | មិនបាច់បំពេញ |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ករណីថ្មីសរុប | | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ករណីសរុប | | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| P: បង់លុយដោយខ្លួនឯង | | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| CBHI: គំរោងធានារ៉ាប់រងសុខភាពសហគមន៍ | | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| V: ប័ណ្ណសុខភាព | | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| E: ករណីលើកលែង | | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

មិនបាច់បំពេញ